shift360

social capital redefined



# មូលនិធិអាហាររូបករណ៍ ណាអូមី តាមី

"សូមកុំសួរខ្លួនអ្នកថា តើពិភពលោកត្រូវការអ្វីតែអ្នកត្រូវសួរខ្លួនអ្នកថាតើមានអ្វីខ្លះដែលធ្វើឲ្យអ្នករស់រានមានជីវិតបន្ទាប់មកចូរអ្នកទៅរករបស់ទាំងនោះនិងធ្វើវាសម្រាប់ពិភពលោកពីព្រោះថាអ្វីដែលពិភពលោកត្រូវការគឺជាអ្វីដែលមនុស្សរស់រានលើផែនដីត្រូវការ។"

– ហ្វូវីដ ថ័រមែន

**មូលនិធិអាហាររូបករណ៍ណាអូមី តាមី** ត្រូវបានចាប់បដិសន្ធិដោយក្រុមគ្រួសារតាមីដើម្បីរំលឹកទៅដល់ កញ្ញា ណាអូមីឡូរា តាមី ដែលបានចែកឋាននៅថ្ងៃទី៧ខែមករាឆ្នាំ២០១៣នៅក្នុងអាយុ២៣ឆ្នាំ។ ដើម្បីរក្សាទុកនូវក្តីស្រលាញ់ និង សេចក្តីប្រាថ្នានៅក្នុងជីវិតរបស់ណាអូមី មូលនិធិអាហាររូបករណ៍ ណាអូមី តាមី នឹងឧបត្ថម្ភថ្លៃសិក្សានិងការចំនាយផ្សេងៗ ដល់វិទ្យាស្ថានម្ហូបអាហារកម្ពុជាចំពោះ សិស្សដែលស្រលាញ់ ផ្នែកម្ហូបអាហារនិងមានការប្តេជ្ញាខ្ពស់ ទៅរកឧត្តមភាពក្នុងការសិក្សា និង សិស្សដែលមិនមានលទ្ធភាព ក្នុងការបង់ថ្លៃសិក្សាព្រោះបញ្ហាហិរញ្ញវត្ថុ។

## មរតករបស់ណាអូមី

ណាអូមី តាមីមានក្តីស្រលាញ់សម្រាប់មនុស្សគ្រប់រូប។ នាងជាមនុស្សពោរពេញ ទៅដោយក្តីស្រលាញ់ ការយកចិត្តទុកដាក់និង ជាអ្នកដឹកនាំម្នាក់ដែលទទួលការសាទរ ច្រើនពីមនុស្សជុំវិញនាង។ កើតនៅក្នុងឆ្នាំ១៩៩០ ប្រទេសសិង្ហបុរី ណាអូមីបានទទួលឈាមជ័រជាអ្នកផ្សងព្រេង ហេតុនេះហើយនៅពេលដែលនាង មានអាយុ៣ឆ្នាំ នាងនឹងក្រុមគ្រួសារបានផ្លាស់ប្តូរមករស់នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មកទៀត នាងបាន ចូលរៀននៅសាលាអន្តរជាតិមួយឈ្មោះ ដាឡាត នៅទីក្រុង ពីណាង ប្រទេសម៉ាឡេស៊ី។

ណាអូមី ពេញប្រៀបទៅដោយក្តីរំភើប ការច្នៃប្រឌិត និងការជំរុញទឹកចិត្ត។ នាងបានធ្វើឲ្យគ្រប់ទីកន្លែង ដែលនាងបានទៅដល់មានភាពស្រស់ថ្លារីករាយ និង មិនដែលបែរខ្នង ចំពោះអ្នកដែលត្រូវការជំនួយ។ ភាពរីករាយ និងអំពើល្អរបស់នាងបានរីកសាយភាយ ទៅគ្រប់ផ្នែកនៃជីវិតរបស់នាង។ ចំពោះផ្នែកម្ហូបអាហារនាង ចូលចិត្តសាកល្បងចម្អិនមុខម្ហូបថ្មីៗសម្រាប់ខ្លួននាង និងសម្រាប់អ្នកដទៃ។ មួយវិញទៀត នៅពេលដែលនាងបានរកឃើញនូវទីក្រុងថ្មី ប្រទេសថ្មី នាងតែងតែបានទៅ ស្វែករកនូវ បទពិសោធ ថ្មី និង អាហារថ្មីនៅទីនោះ។

ភាពរីករាយ និងអំពើល្អចំពោះជីវិត និងអ្នកដែលនាងស្រលាញ់ក្នុងនោះរួមមានអាហារនិង ដំណើរផ្សងព្រេងបាន

ដឹកនាំណាអូមីឲ្យជ្រើសរើសអាជីពការងារ ផ្នែកម្ហូបអាហារនិង បដិសណ្ឋារកិច្ច។  នាងបានបញ្ចប់ការសិក្សានៅសាលាអន្តរជាតិផ្នែកគ្រប់គ្រងសណ្ឋាគារ ហើយមុនពេលបញ្ចប់ការសិក្សា នាងបានចុះហាត់ការនៅសណ្ឋាគារលំដាប់ផ្កាយប្រាំជាច្រើនដូចជានៅឡូសាណេ ស្វីស សៀងហៃ ចិន តៃប៉ិ តៃវ៉ាន់ និង ស៊ីដនីប្រទេសអូស្ត្រាលីជាដើម។

មូលនិធិអាហាររូបករណ៍ ណាអូមី តាមី តំណាងឲ្យការបន្សល់ទុកនូវភាពរីករាយ សេចក្តីមេត្តា ការទំនាក់ទំនងជាមួយអ្នកដទៃ ភាពកក់ក្តៅ និង ចំណង់ទៅលើបទពិសោធថ្មីៗ និង ការផ្សងព្រេងរបស់ណាអូមី។

ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុរបស់អ្នកមកកាន់មូនិធិ អាហាររូបករណ៍ ណាអូមី នឹងធ្វើឲ្យមូលនិធិ សិប្បរបីរយហុកពង្រីកឱកាស អាហាររូបករណ៍សម្រាប់វិទ្យាស្ថានម្ហូបអាហារកម្ពុជា និង ផ្តល់ឱកាសដល់សិស្ស ដែលមានបញ្ហាផ្នែកហិរញ្ញវត្ថុឲ្យពួកគេទទួលបាន អនាគតល្អប្រសើរមួយ។

**ទំនាក់ទំនង៖** scholarship@shift360.ch